**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៧៦ ពណ.ជ.ផ.ព

ថ្ងៃ ចន្ទ ១ កើត ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបន្តសុពលភាពនៃការចុះបញ្ជីពាណិជ្ជកម្មសាឡើងវិញ តាមប្រព័ន្ធស្វ័យប្រវត្តកម្ម រហូតដល់ថ្ងៃច័ន្ទ ៩រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនក្រុមហ៊ុន ឬទីភ្នាក់ងារទាំងឡាយដែលមិនទាន់បានចុះបញ្ជីសាឡើងវិញមេត្តាជ្រាបថា ក្រសួងពាណិជ្ជកម្មពិនិត្យឃើញថា រហូតមកទល់ពេលនេះមានក្រុមហ៊ុនភាគច្រើនបានធ្វើការចុះបញ្ជីពាណិជ្ជកម្មសាឡើងវិញ តាមកាលកំណត់របស់ក្រសួងពាណិជ្ជកម្ម ដូចមានក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្មលេខ ៣០០ ពណ.ចបព.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការចុះបញ្ជីពាណិជ្ជកម្មសាឡើងវិញក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម និងសេចក្តីជូនដំណឹងនៃការពន្យារពេល រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។

ដើម្បីផ្តល់ឱកាសជូនក្រុមហ៊ុន ឬទីភ្នាក់ងារទាំងឡាយដែលមិនទាន់បានចុះបញ្ជីពាណិជ្ជកម្មសាឡើងវិញ ក្រសួងពាណិជ្ជកម្ម សម្រេចបន្តសុពលភាពការចុះបញ្ជីពាណិជ្ជកម្មសាឡើងវិញ តាមប្រព័ន្ធស្វ័យប្រវត្តកម្មរហូតដល់ **ថ្ងៃច័ន្ទ ៩រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**។ ប៉ុន្តែក្រុមហ៊ុន ឬទីភ្នាក់ងារទាំងឡាយ ត្រូវភ្ជាប់ប្រតិវេទន៍អំពីស្ថានភាព សហគ្រាសពាណិជ្ជកម្ម ប្រចាំឆ្នាំ២០១៥ ឆ្នាំ២០១៦ និងឆ្នាំ២០១៧។

ក្នុងករណីក្រុមហ៊ុន ដែលមិនមានប្រតិវេទន៍អំពី ស្ថានភាពសហគ្រាសពាណិជ្ជកម្មប្រចាំឆ្នាំ២០១៥ ឆ្នាំ២០១៦ និងឆ្នាំ២០១៧ ក្រុមហ៊ុនត្រូវបង់កម្រៃសេវាតម្កល់ប្រតិវេទន៍ទាំង ០៣ (បី) ឆ្នាំ និងការពិន័យចំពោះការមិនតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ នៅក្រសួងពាណិជ្ជកម្ម ដូចមានកំណត់ក្នុងប្រកាសរួមលេខ ១២១៧ សហវ.ប្រក រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ឬលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតជាធរមាន។

ក្រសួងពាណិជ្ជកម្មសង្ឃឹមយ៉ាងមុតមាំថា ក្រុមហ៊ុន សហគ្រាស សាខា ការិយាល័យតំណាង បុគ្រលម្ព័ន្ធ ឬទីភ្នាក់ងារទាំងអស់ បានជ្រាបជាដំណឹង ហើយរួសរាន់មកចុះបញ្ជីសាឡើងវិញ តាមប្រព័ន្ធស្វ័យប្រវត្តកម្មតាមកាលកំណត់ជាក់ជាមិនខាន។

សេចក្តីជូនដំណឹងនេះនឹងត្រូវអនុវត្តចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។